# សេចក្តីប្រកាស
# ជ្រើសរើសអ្នកបើកបរ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ត្រូវការជ្រើសរើសអ្នកបើកបរ ដើម្បីបម្រើការងារឲ្យវិទ្យាស្ថាន។

**ភារកិច្ចសំខាន់ៗ៖**

- បើកបរយានយន្តប្រកបដោយវិជ្ជាជីវៈ សុវត្ថិភាព ការទទួលខុសត្រូវខ្ពស់ និងការគោរពពេលវេលាយ៉ាងទៀងទាត់ ជូន បុគ្គលិក ភ្ញៀវ និងគណៈប្រតិភូជាតិ និងអន្តរជាតិ
- បញ្ជូន និងប្រមូលលិខិត ឯកសារ និងសម្ភារផ្សេងៗ
- ជួសជុលកម្រិតមូលដ្ឋាន និងថែទាំយានយន្តឲ្យបានល្អប្រសើរជាប្រចាំ
- ជួយការងាររដ្ឋបាលផ្សេងៗតាមការចាត់ចែងរបស់មន្ត្រីរដ្ឋបាល។

**លក្ខណៈសម្បត្តិត្រូវមាន៖**

- កម្រិតវប្បធម៌មធ្យមសិក្សាបឋមភូមិ
- មានចំណេះដឹងភាសាអង់គ្លេសកម្រិតមូលដ្ឋាន
- មានបទពិសោធន៍ក្នុងការបើកបររយៈពេល ២-៣ឆ្នាំ (ជាពិសេស ក្នុងការបើកបរជូនថ្នាក់ដឹកនាំអង្គភាព)
- ចេះជួសជុលយានយន្តកម្រិតមូលដ្ឋាន និងមានការយល់ដឹងក្នុងការថែទាំយានយន្ត
- មានប័ណ្ណបើកបរនៅមានសុពលភាព និងមានប្រវត្តិបើកបរល្អ
- ស្គាល់ទីតាំងភូមិសាស្ត្រក្នុងរាជធានីភ្នំពេញ និងខេត្ត/ក្រុង (ជាពិសេស ស្គាល់អាសយដ្ឋានក្រសួង ស្ថាប័ន រដ្ឋ ស្ថានទូត អង្គភាពជាតិ និងអន្តរជាតិ និងក្រុមហ៊ុននានា)
- មានអត្តចរិតល្អ ឧស្សាហ៍ព្យាយាម និងអត់ធ្មត់នឹងការងារ
- មានសុខភាព និងកាយសម្បទាមាំមួន។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវ ប្រវត្តិរូបសង្ខេប ១ច្បាប់ មានបិទរូបថតទំហំ ៤x៦សម អត្តសញ្ញាណប័ណ្ណថតចម្លង ១ច្បាប់ ប័ណ្ណបើកបរថតចម្លង ១ច្បាប់ ឈ្មោះអ្នកធានាចំនួនបីរូប និងលេខទូរស័ព្ទទំនាក់ទំនង។ សំណុំពាក្យសុំនេះ សូមផ្ញើមក វិទ្យាស្ថាន CDRI តាមរយៈអ៊ីម៉េល hr@cdri.org.kh ឬតាមអាសយដ្ឋានផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក រាជធានីភ្នំពេញ ត្រឹមថ្ងៃទី**០២ ខែវិច្ឆិកា ឆ្នាំ២០១៨**។

**សម្រាប់បេក្ខជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នានា វិទ្យាស្ថាននឹងទាក់ទងអញ្ជើញឲ្យមកធ្វើសម្ភាសន៍ ពាក្យស្នើសុំនិងឯកសារភ្ជាប់មិនប្រគល់ជូនវិញទេ។**